ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២៨ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

០៣ - ៨ - ៩៥ អនុក្រឹត្យលេខ ៦៣ អនក្រ. បក ស្តីពីរបៀបរបប និងការរៀបចំបោះឆ្នោតសភាពាណិជ្ជកម្ម ១២៧៧

II - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១ - សេចក្តីសំរេច

០៤ - ៨ - ៩៥ សេចក្តីសំរេចលេខ ១០០ សសរ. សហវ. ថ ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវ និងត្រួតពិនិត្យសកម្មភាពរបស់បណ្តាក្រុមហ៊ុនទូរស័ព្ទចល័ត ១២៨៤

០៨ - ៨ - ៩៥ សេចក្តីសំរេច ១០២ សហវ. សស. ប ស្តីពីការបង្កើតគណៈកម្មការចំរុះសំរាប់ត្រួតពិនិត្យបញ្ជីគណនេយ្យ និងបិទបញ្ជីគណនេយ្យ ឆ្នាំ ១៩៩៣-៩៤ និងណែនាំត្រៀមបិទបញ្ជីគណនេយ្យ ឆ្នាំ ១៩៩៥ ១២៨៦

២ - ប្រកាស

០២ - ៨ - ៩៥ ប្រកាសលេខ ២៧៦ ប្រក. សហវ. ពដ ស្តីពីការកំណត់ពន្ធចំពោះអាជីវកម្មនេសាទ ១២៨៩

០៣ - ៨ - ៩៥ ប្រកាស លេខ ២៧៩ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន ១២៩០

០៧ - ៨ - ៩៥ ប្រកាស លេខ ២៨២ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន ១២៩៣

០៧ - ៨ - ៩៥ ប្រកាស លេខ ២៨៥ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន ១២៩៤

០៧ - ៨ - ៩៥ ប្រកាស លេខ ២៨៦ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន ១២៩៦

២ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

០១ - ៨ - ៩៥ ប្រកាសលេខ ៥៥៤ ករ.ប្រក អនុញ្ញាតអោយក្រុមហ៊ុន SUNTRADING Co.LTD. ធ្វើប្រតិបត្តិការរុករកធនធានរ៉ែនៅតំបន់មេម៉ង់ ខេត្តមណ្ឌលគិរី ១២៩៨

០៣ - ៨ - ៩៥ ប្រកាសលេខ ៥៩៨ ផក.ប្រក អនុញ្ញាតអោយលោក ហុង សុខ ជនជាតិខ្មែរ បើកដំណើរការផលិតកម្មឡឥដ្ឋ ក្បឿង ១៣០០

០៤ - ៨ - ៩៥ ប្រកាសលេខ ៦០០ ផក.ប្រក អនុញ្ញាតអោយលោក តាំង គុយលីម ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតគ្រឿងក្រអូប សញ្ញា «ស្វរិយា» ១៣០០

០៤ - ៨ - ៩៥ ប្រកាសលេខ ៦០៦ ផក.ប្រក អនុញ្ញាតអោយលោក សុខ ហៃ ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មកែច្នៃស្រា សូនីវីស្គី 'SONY WHISKY' ១៣០១

០៧ - ៨ - ៩៥ ប្រកាសលេខ ៦០៧ បល.ប្រក ស្ដីពីការបង្កើតគណៈកម្មការរៀបចំតំរោងការតាំងពិពរណ៌ WORLDTECH 95 នៅប្រទេសថៃឡង់ដ៍ ១៣០២

០៨ - ៨ ០ ៩៥ ប្រកាសលេខ ៦០៨ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ខូត សំផល ជនជាតិខ្មែរ បើកដំណើរការឡផលិតឥដ្ឋក្បឿង ១៣[illegible]

៣ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

០២ - ៨ -៩៥ ប្រកាសលេខ ១៦៦/៩៥ ពម.ប្រក ស្ដីពីការផ្ទេរការងាររបស់មន្ត្រីរាជការ ១៣០៤

០២ - ៨ - ៩៥ ប្រកាសលេខ ១៦៧/៩៥ ពម.ប្រក ស្ដីពីការផ្ទេរការងាររបស់មន្ត្រីរាជការ ១៣០៥

០២ - ៨ - ៩៥ ប្រកាសលេខ ១៧០/ពម.ប្រក ស្ដីពីការទទួលស្គាល់មន្ត្រីរាជការ ១៣០៦

០៥ - ៨ - ៩៥ ប្រកាសលេខ ១៧៦/៩៥ ពម.ប្រក ស្តីពីការតាំងស៊ុបក្នុងក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង ១៣០៧

០៧ - ៨ - ៩៥ ប្រកាសលេខ ១៧៧/៩៥ ពម.ប្រក អនុញ្ញាតអោយលោក ព្រហ្មខេមរៈ ផ្ទេរសិទ្ធិចាងហ្វាងការផ្សាយសារពត៌មាន«សំរែករាជសីហ៍» អោយទៅឈ្មោះ ច៉ានផល្គុន វិញ ១៣០៨

០៧ - ៨ - ៩៥ ប្រកាសលេខ ១៧៨/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង ១៣០៩

០៧ - ៨ - ៩៥ ប្រកាសលេខ ១៧៩/៩៥ ពម.ប្រក អនុញ្ញាតអោយដំណើរការបោះពុម្ពចែកផ្សាយទស្សនាវដ្តីប្រចាំឆ្នាំឈ្មោះ THE BUSINESS NEWS QUIDE ជាភាសាខ្មែរ និងអង់គ្លេស ១៣១០

០៧ - ៨ - ៩៥ ប្រកាសលេខ ១៨០/៩៥ ពម.ប្រក ស្តីពីការទទួលស្គាល់មន្ត្រីរាជការ ១៣១១

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សារាចរ

០៥ - ៨ - ៩៥ សារាចរលេខ ០៣ សរច ស្តីពីការបើកមហោស្រពតែងនិពន្ធអក្សរសិល្ប៍ «ព្រះរាជសម្ភារ» ១៣១៣

០៨ - ៨ - ៩៥ សារាចរណែនាំលេខ ០៤ សរច.ន ស្តីពីការការពារបេតិកភ័ណ្ឌជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា ១៣១៦

០៧ - ៨ - ៩៥ ប្រកាសលេខ ១៤៤ ប្រក.វវស.ប ស្តីពីការលុបឈ្មោះមន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញ ១៣១៨

៥ - ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

០១ - ៨ - ៩៥ ប្រកាសលេខ ១៦១/៩៥ កធស.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងធម្មការ និង សាសនា ១៣១៩

០៣ - ៨ - ៩៥	សេចក្ដីសំរេចលេខ ១៦២/៩៥ កធស.ធផ ស្ដីពីការទទួលស្គាល់ «សមាគម ដូនជី និង ឧបាសិកាកម្ពុជរដ្ឋ »	១៣២០
០៨ - ៨ - ៩៥	ប្រកាសលេខ ១៦៤/៩៥ ធធស.ប្រក ស្ដីពីការផ្ទេរមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌក្រសួងធម្មការ និង សាសនា	១៣២១

I - ឯកសារគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦៣ អនក្រ.បក

ស្តីពី

របៀបរៀប និង ការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា .
- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- បានឃើញ ច្បាប់ស្តីពីសភាពាណិជ្ជកម្មដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស.រកម-០៦៩៥-០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ .
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម .
- គណៈរដ្ឋមន្ត្រីយល់ព្រមផង .

សំរេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : សភាពាណិជ្ជកម្ម មានសមាជិកជ្រើសតាំងតាមការបោះឆ្នោត និង សមាជិកទីប្រឹក្សា ។ ចំនួនសមាជិកជ្រើសតាំងតាមការបោះឆ្នោត ត្រូវបានកំណត់ដោយអនុក្រឹត្យបង្កើតសភាពាណិជ្ជកម្មនិមួយ ។ ហើយចំនួនសមាជិកទីប្រឹក្សា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

អាណត្តិរបស់សមាជិកសភាពាណិជ្ជកម្មមានរយៈពេល ០៦ ឆ្នាំ ។ រៀងរាល់ ០៣ ឆ្នាំម្តង សភាពាណិជ្ជកម្មត្រូវរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំង ថ្មីចំនួនពាក់កណ្តាលលើកលែងតែនៅក្នុងអាណត្តិដំបូងត្រូវមានការចាប់ឆ្នោត ជ្រើសរើសសមាជិកចំនួនពាក់កណ្តាល ដែលត្រូវបញ្ចប់អាណត្តិក្រោយរយៈ ពេល ០៣ ឆ្នាំ ។

មាត្រា ២ : សមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្ម ត្រូវចូលបំពេញការងាររបស់ខ្លួនក្រោយថ្ងៃប្រកាសលទ្ធផលបោះឆ្នោតយ៉ាងយូរមួយខែ ក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង និងអភិបាលខេត្ត - ក្រុង ឬ តំណាងនៃមណ្ឌលរបស់សាមីសភាពាណិជ្ជកម្ម ។

មាត្រា ៣ : ក្នុងករណីដែលចំនួនសមាជិកជ្រើសតាំងធ្លាក់មកនៅទាបជាងពាក់កណ្តាលសភាពាណិជ្ជកម្មត្រូវបានរំសាយដោយអនុក្រឹត្យរបស់គណៈរដ្ឋមន្ត្រី តាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្ម ។ ការជ្រើសតាំងសមាជិកជាថ្មីត្រូវធ្វើក្នុងរយៈពេល ០៣ ខែយ៉ាងយូរ គិតពីថ្ងៃចេញអនុក្រឹត្យ ។

ក្រសួងពាណិជ្ជកម្ម ត្រូវប្រកាសតែងតាំងគណៈកម្មការបណ្តោះអាសន្នមួយដើម្បីដឹកនាំសភាពាណិជ្ជកម្មជាបន្ទាន់ ។

ជំពូក ២

គណៈកម្មការរៀបចំការបោះឆ្នោត

មាត្រា ៤ : គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជ

កម្ម មានសមាសភាពដូចខាងក្រោម ÷

– តំណាងក្រសួងពាណិជ្ជកម្ម	ជាប្រធាន
– តំណាងក្រុមប្រឹក្សាអ្នកច្បាប់	ជាអនុប្រធាន
– តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
– តំណាងក្រសួងមហាផ្ទៃ	ជាសមាជិក
– តំណាងរាជធានីភ្នំពេញ	ជាសមាជិក
– តំណាងក្រសួងទេសចរណ៍	ជាសមាជិក
– តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន	ជាសមាជិក
– តំណាងធនាគារជាតិ	ជាសមាជិក
– តំណាងក្រសួងឧស្សាហកម្ម	ជាសមាជិក
– តំណាងក្រសួងកសិកម្ម	ជាសមាជិក
– តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	ជាសមាជិក
– តំណាងក្រសួងវប្បធម៌	ជាសមាជិក
– តំណាងក្រសួងអប់រំ	ជាសមាជិក
– តំណាងក្រសួងយុត្តិធម៌	ជាសមាជិក
– មន្ត្រីក្រសួងពាណិជ្ជកម្មចំនួន ០២ រូប	ជាលេខាធិការ

មាត្រា ៥ : គណៈកម្មការរៀបចំការបោះឆ្នោត មានភារកិច្ចដូចតទៅ ÷

– ណែនាំលំអិត ស្តីពីបែបបទបោះឆ្នោតដល់សាធារណជន

– ធ្វើបញ្ជីអ្នកមានសិទ្ធិបោះឆ្នោតតាមប្រភេទអាជីវកម្មនីមួយ ៗ ប្រភេទពាណិជ្ជកម្ម ប្រភេទឧស្សាហកម្ម និង សិប្បកម្ម ប្រភេទសេវាកម្ម និងវិជ្ជាជីវៈសេរី ប្រភេទកសិកម្ម ។ បញ្ជីនេះត្រូវចុះហត្ថលេខាបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

– ធ្វើប័ណ្ណគ្រប់ជំពូកសំរាប់ការបោះឆ្នោត

– ធ្វើបញ្ជីបេក្ខជនឈរឈ្មោះ ជាសមាជិកជ្រើសតាំងរបស់សភាពាណិជ្ជកម្ម ។ បញ្ជីនេះត្រូវចុះហត្ថលេខាបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

– ចាត់ចែងវិធានការសំរាប់ត្រួតពិនិត្យមើលការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ។

– រៀបចំការិយាល័យបោះឆ្នោត ។

- ដើម្បីបំពេញភារកិច្ចរបស់ខ្លួនអោយមានប្រសិទ្ធភាព គណៈកម្មការរៀបចំការបោះឆ្នោតមានសិទ្ធិលុបឈ្មោះបេក្ខជនណាមួយចេញពីបញ្ជីបេក្ខជន ក្នុងករណីដែលសាមីខ្លួនមិនគោរពបែបបទនិងការណែនាំរបស់គណៈកម្មការក្នុងការបោះឆ្នោត ។

មាត្រា ៦ : កំណត់យកក្រសួងពាណិជ្ជកម្ម ជាទីតាំងរបស់គណៈកម្មការសំរាប់ការបោះឆ្នោតនៅអាណត្តិទីមួយ ។ ចំពោះការបោះឆ្នោតសំរាប់អាណត្តិក្រោយៗទៀត ទីតាំងសំរាប់គណៈកម្មការនេះត្រូវកំណត់ដោយសភាពាណិជ្ជកម្ម ។

សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំ និងបំពេញការងារតាមការកំណត់របស់ប្រធាន ។

សេចក្តីសំរេចរបស់គណៈកម្មការ នឹងមានសុពលភាពបានលុះណាតែ មានសមាជិកចំនួនពាក់កណ្តាលយ៉ាងតិចមកចូលរួមប្រជុំ ។

មាត្រា ៧ : រាល់ការចំណាយរបស់គណៈកម្មការក្នុងការរៀបចំបោះឆ្នោត នៅអាណត្តិទី ១ នេះជាបន្ទុករបស់ថវិការដ្ឋ ។ ការចំណាយសំរាប់ការបោះឆ្នោតនៅអាណត្តិក្រោយ ៗ ទៀត ជាបន្ទុករបស់សភាពាណិជ្ជកម្មសាមី ។

ជំពូក ៣

ការបោះឆ្នោត

មាត្រា ៨ : អ្នកមានសិទ្ធិបោះឆ្នោត ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

១- មានសញ្ជាតិជាខ្មែរ

២- មានអាយុយ៉ាងតិច ១៨ ឆ្នាំ

៣- ជាពាណិជ្ជករ ឧស្សាហករ សិប្បករ អ្នកធ្វើសេវាកម្ម អ្នកធ្វើអាជីវកម្មកសិកម្ម ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ។ ជាបណ្តោះអាសន្នចំពោះការ រើសសមាជិកសភាពាណិជ្ជកម្មសំរាប់អាណត្តិទី១ អាចមានសិទ្ធិបោះឆ្នោតបានដែរ ពាណិជ្ជករ ឧស្សាហករ សិប្បករ អ្នកធ្វើសេវាកម្ម អ្នកធ្វើអាជីវកម្ម កសិកម្ម ដែលបានទទួលការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចណាមួយ អោយធ្វើអាជីវកម្ម ហើយដែលមានទីស្នាក់ការ ឬអាគារធ្វើអាជីវកម្មនៅ រាជធានីភ្នំពេញ ។

ឬជាម្ចាស់សហគ្រាសដែលមានសញ្ជាតិខ្មែរ ចំពោះអាជីវករដែលពុំមែនជាក្រុមហ៊ុន ។

ឬ ជាប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាលចំពោះក្រុមហ៊ុន អនាមិក និងជានាយក ឬជាបណ្ណាធិការ ចំពោះក្រុមហ៊ុនប្រភេទផ្សេងទៀតដែលមានសញ្ជាតិខ្មែរ ។

មាត្រា ៩ : អ្នកមានសិទ្ធិបោះឆ្នោត ត្រូវសុំចុះឈ្មោះបោះឆ្នោតនៅក្នុងបញ្ជីអ្នកបោះឆ្នោតរបស់គណៈកម្មការរៀបចំការបោះឆ្នោត តាមការកំណត់របស់គណៈកម្មការនេះ ។ នៅក្រោយពេលបញ្ចប់ការចុះ ឈ្មោះ បញ្ជីអ្នកបោះឆ្នោតត្រូវបិទផ្សាយនៅក្រសួងពាណិជ្ជកម្ម និងនៅសាលាខេត្ត ក្រុង ។ ក្នុងករណីមានការតវ៉ា រាល់អ្នកមានសិទ្ធិបោះឆ្នោតអាចប្ដឹងតវ៉ាមកគណៈកម្មការ ក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃដែលបានបិទផ្សាយបញ្ជី ។

ហួសពីរយៈពេលនេះ គណៈកម្មការបោះឆ្នោតបញ្ចប់បញ្ជីជាស្ថាពរ ។ រាល់ការតវ៉ាត្រូវឈប់ទទួល ។

មាត្រា ១០ : បេក្ខជនសមាជិកជ្រើសតាំង ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ÷

១– បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ

២– មានអាយុយ៉ាងតិច ៣០ ឆ្នាំ

៣– បានបង់ថ្លៃសិទ្ធិឈរឈ្មោះបោះឆ្នោតតាមការកំណត់របស់គណៈកម្មការបោះឆ្នោត ។

៤– មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ

មាត្រា ១១ : បេក្ខជនដែលចង់ឈរឈ្មោះជាសមាជិកជ្រើសតាំង ត្រូវសុំចុះឈ្មោះជាបេក្ខជនក្នុងបញ្ជីបេក្ខជនរបស់គណៈកម្មការរៀបចំការបោះឆ្នោត តាមការកំណត់របស់គណៈកម្មការនេះ ។ ការសុំចុះឈ្មោះនេះត្រូវធ្វើដោយសាមីបេក្ខជនផ្ទាល់ និងចុះហត្ថលេខាដោយផ្ទាល់ដៃលើសំណុំបែបបទផ្សេងៗ ។

បញ្ជីបណ្ដោះអាសន្ននៃបេក្ខជនត្រូវបញ្ចប់ ១៥ ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ បញ្ជីនេះត្រូវបិទផ្សាយនៅក្រសួងពាណិជ្ជកម្ម និងនៅសាលាខេត្ត ក្រុង ។

យ៉ាងយូរ ០៧ ថ្ងៃមុនថ្ងៃបោះឆ្នោតបេក្ខជនមានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រីក្រសួង

ពាណិជ្ជកម្ម អំពីការរារាំងមិនអោយខ្លួនចុះឈ្មោះ ឬភ្លេចចុះឈ្មោះខ្លួននៅក្នុងបញ្ជីនេះ ។

បញ្ជីបេក្ខជនជាស្ថាពរត្រូវបញ្ចប់ ០៧ ថ្ងៃ មុនពេលបោះឆ្នោត ។ ចាប់ពីថ្ងៃបញ្ចប់តទៅមិនអនុញ្ញាតអោយធ្វើការតវ៉ាទេ ។ បញ្ជីស្ថាពរនេះត្រូវបិទផ្សាយនៅទីកន្លែងដែលបានបិទផ្សាយបញ្ជីបណ្ដោះអាសន្ន ។

ប្រការ ១២ : ការបោះឆ្នោតមានដំណើរប្រព្រឹត្តទៅដូចខាងក្រោម ÷

១– ការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងរបស់សភាពាណិជ្ជកម្ម ត្រូវអនុវត្តតាមគោលការណ៍ :

* យកសម្លេងភាគច្រើន
* បោះតាមឈ្មោះនិមួយ ៗ
* បោះតែមួយជុំ

ក្នុងករណីដែលមានបេក្ខជនច្រើននាក់ទទួលសម្លេងឆ្នោតស្មើគ្នានោះ ត្រូវជ្រើសតាំងបេក្ខជនដែលមានអាយុច្រើនជាង ។

២– ការិយាល័យបោះឆ្នោតត្រូវបានរៀបចំតែមួយកន្លែង ហើយរយៈពេលបោះឆ្នោតត្រូវកំណត់តែមួយថ្ងៃ គឺចាប់ពីម៉ោង ៨ ព្រឹកដល់ម៉ោង ១៥ ល្ងាច ។

៣–ការឃោសនាបោះឆ្នោតជាសាធារណៈ ត្រូវកំណត់ចាប់ផ្ដើម ១៥ ថ្ងៃមុនថ្ងៃបោះឆ្នោត តាមប្រតិទិនរបស់គណៈកម្មការរៀបចំការបោះឆ្នោត ហើយត្រូវបញ្ចប់ ០៣ ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៤– អ្នកបោះឆ្នោតត្រូវយកប័ណ្ណបោះឆ្នោតមកជាមួយសំរាប់ដូរយកសន្លឹកឆ្នោត ។ អ្នកមានសិទ្ធិបោះឆ្នោតដែលពុំអាចមកបោះឆ្នោតផ្ទាល់ខ្លួនបានដោយមូលហេតុអ្វីមួយ អាចប្រគល់សិទ្ធិតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ អោយអ្នកដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងប្រភេទអាជីវកម្មដូចគ្នា មកបោះជំនួសខ្លួនបាន ។ អ្នកទទួលសិទ្ធិអាចបោះឆ្នោតជំនួសបានតែម្នាក់ ។

៥– បើសិនជាអ្នកបោះឆ្នោតណាម្នាក់ភ្លេចមិនបានយកប័ណ្ណបោះឆ្នោតជាប់ជាមួយខ្លួន អ្នកបោះឆ្នោតនេះ ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណរបស់ខ្លួនជាជំនួសដើម្បីបោះឆ្នោត ។

៦- បេក្ខជននិមួយៗ មានសិទ្ធិចាត់តំណាងម្នាក់ អោយចូលសង្កេតការណ៍ការបោះឆ្នោតជាមួយគណៈកម្មការ ។

៧- ការរាប់សន្លឹកឆ្នោត ត្រូវរាប់អោយចប់នៅថ្ងៃបោះឆ្នោត ហើយយោងតាមកំណត់ហេតុនៃគណៈកម្មការបោះឆ្នោត រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតនេះនៅថ្ងៃដដែល ។
លទ្ធផលនេះត្រូវចាត់ទុកជាស្ថាពរ ពុំអាចត្រូវបានតវ៉ានៅចំពោះមុខអង្គការណាមួយឡើយ ។ ការទទួលស្គាល់សមាជិកជ្រើសតាំងរបស់សភាពាណិជ្ជកម្ម ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

ជំពូក ៤

អវសានប្បញ្ញត្តិ

មាត្រា ១៣ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ១៤ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ អភិបាលរាជធានីភ្នំពេញ ក្រសួងទេសចរណ៍ ក្រសួងសាធារណការ និង ដឹកជញ្ជូន ធនាគារជាតិ ក្រសួងឧស្សាហកម្ម ក្រសួងកសិកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងវប្បធម៌ ក្រសួងអប់រំ ក្រុមប្រឹក្សាអ្នកច្បាប់ ក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

II - ការងារបណ្ដាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១ - សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្ដីសំរេច លេខ ១០០ សសរ.សហវ.ប
ស្ដីពីការបង្កើតគណៈកម្មការចុះស្រាវជ្រាវ និង
ត្រួតពិនិត្យ[illegible]ការបង់របស់បណ្ដាក្រុមហ៊ុនទូរស័ព្ទចល័ត

...

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញ **រដ្ឋធម្មនុញ្ញ** នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល .
- យោងស្មារតីអង្គប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៥ .

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយ ដើម្បីចុះស្រាវជ្រាវត្រួតពិនិត្យការប្រមូលពន្ធនាំចូល និងការប្រើប្រាស់សេវាទូរស័ព្ទចល័តទាំងអស់ដែលមានសមាសភាពដូចតទៅ÷

១- លោក **ម៉ម និច** អនុប្រធានគណៈកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ ប្រធាន

២- លោក **កែវ ដារ** មន្ត្រីគណៈកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ សមាជិក

៣- លោក **ឡូញ ទណ្ណៈ** អនុប្រធានការិយាល័យត្រួតពិនិត្យនៃទីចាត់ការគយ និងរដ្ឋាករ សមាជិក

៤– លោក អ៊ុយ កុសល មន្ត្រីនៃទីចាត់ការគយនិងរដ្ឋាករ សមាជិក

៥– លោក ពេជ ចន្ទតារា អនុប្រធានការិយាល័យនៃនាយកដ្ឋានពន្ធដារ សមាជិក

៦– លោក ឈាន គីម មន្ត្រីនៃនាយកដ្ឋានពន្ធដារ សមាជិក

៧– លោក នៅ ស៊ីថន មន្ត្រីនៃនាយកដ្ឋានហិរញ្ញកិច្ច សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ដូចតទៅ ÷

១– សហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីចុះជំរុញឱ្យបណ្តាក្រុមហ៊ុនទូរស័ព្ទទាំងអស់អនុវត្តឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលានូវកាតព្វកិច្ចបង់ :

– ពន្ធនាំចូល ពន្ធលើផលរបរ និងពន្ធលើប្រាក់ចំណេញ

– ភាគរយនៃចំណូលដែលត្រូវបង់ជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

២– តាមដាន និងត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើបរិមាណបរិធានទូរស័ព្ទដែលធ្វើការនាំចូល និង ស្តុកជាក់ស្តែង ។

៣–លើកឡើងនូវសំណូមពរ និងវិធានការអនុវត្ត ដើម្បីសុំការសំរេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះបណ្តាក្រុមហ៊ុនទូរស័ព្ទដែលពុំបានគោរព ប្រតិបត្តិ តាមការកំណត់ឱ្យធ្វើអាជីវកម្ម សេវាកម្ម ក៏ដូចជាការអនុវត្តន៍ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ ។

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានគណៈកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ នាយកទីចាត់ការគយនិងរដ្ឋាករ និងអស់លោកដូចមានឈ្មោះក្នុងប្រការ ១ ខាងលើ ត្រូវទទួលភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

គាត ឈន់

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ១០២ សហវ.សសរ.ប

ស្តីពី

ការបង្កើតគណៈកម្មការចំរុះ សំរាប់ចុះត្រួតពិនិត្យបញ្ជីគណនេយ្យ និង បិទបញ្ជីគណនេយ្យ ឆ្នាំ ១៩៩៣–៩៤ និង ណែនាំត្រៀមបិទបញ្ជីគណនេយ្យ ឆ្នាំ ១៩៩៥

***

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល .
- យោងលិខិតលេខ ២៩៦ សហវ.ប ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងស្មារតីអង្គប្រជុំរបស់ក្រសួង នាថ្ងៃ អង្គារ៍ ទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៥ .

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះរបស់ក្រសួងសំរាប់ចុះត្រួតពិនិត្យបញ្ជីគណនេយ្យ និង បិទបញ្ជីគណ នេយ្យ ឆ្នាំ ១៩៩៣–៩៤ និង ណែនាំត្រៀមបិទបញ្ជីគណនេយ្យ ឆ្នាំ ១៩៩៥ ដែលមានសមាសភាពដូចមានរាយនាមខាងក្រោម :

១-លោក	**យិនន៍ គាំយលេង**	ប្រធាននាយកដ្ឋានរបបគណនេយ្យ	ជាប្រធាន
២-លោក	**ម៉ម និម**	អនុប្រធានគណៈកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ	សមាជិក
៣-លោក	**តាំង លាងខ័ណ្ឌ**	អនុប្រធាននាយកដ្ឋានទ្រព្យរដ្ឋ	សមាជិក
៤-លោក	**លឹម ម៉ុងហៃ**	អនុប្រធាននាយកដ្ឋានចំការរដ្ឋ	សមាជិក
៥-លោក	**ម៉ម ម៉ុន**	អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ច	សមាជិក

ប្រការ ២ : គណៈកម្មការចំរុះខាងលើ មានភារកិច្ចប្រជុំដឹកនាំ ណែនាំ និង បែងចែកដល់ក្រុមការងារ ដូច មានរាយនាមខាងក្រោម ដែលត្រូវចុះតាមស្ថាប័ន ក្រសួង អង្គភាពរដ្ឋ ឬ រដ្ឋចំរុះជាមួយឯកជន ធ្វើអាជីវកម្ម

ក - នាយកដ្ឋានរបបគណនេយ្យ :

១-លោកស្រី	**ឌិន រម្មនា**	អនុប្រធានការិយាល័យ
២-លោកស្រី	**ខ្ងិត មុំ**	អនុប្រធានការិយាល័យ
៣-លោក	**បេង ម៉ុនថន**	អនុប្រធានការិយាល័យ
៤-លោក	**មាស សេដ្ឋា**	អនុប្រធានការិយាល័យ
៥-កញ្ញា	**លី សុសៃយាន្ត**	បុគ្គលិក
៦-លោក	**គាត មុនីកោសល្យ**	បុគ្គលិក
៧-លោក	**ម៉ី សុជាតិ**	បុគ្គលិក
៨-លោក	**ស៊ុន ស៊ីថា**	បុគ្គលិក
៩-លោក	**ចូ សារ៉ាផៃ**	បុគ្គលិក
១០-លោកស្រី	**ម៉ៅ ពុទ្ធី**	បុគ្គលិក
១១-លោកស្រី	**នាយ ផល្លី**	បុគ្គលិក
១២-លោក	**គួច ទ៊ាម៉ូរី**	បុគ្គលិក

ខ - គណៈកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ :

១-លោក	**ចាន់ សុខុម**	អនុប្រធាននាយកដ្ឋាន

២-លោក សែម ឌីណេ ប្រធានការិយាល័យ

៣-លោក ទី ចំរើន អនុប្រធានការិយាល័យ

៤-លោក យឹម សើររដ្ឋ បុគ្គលិក

៥-លោក ហ៊ាង ឈានឃ្មួរ បុគ្គលិក

៦-លោក ទ្រឹក លីណូ បុគ្គលិក

៧-លោក ប៉ាល់ ស៊ុនៅ បុគ្គលិក

៨-លោក សេខ ទ៉ាន់ថន បុគ្គលិក

៩-លោក គី ចាន់ណារ៉ា បុគ្គលិក

១០-លោក គា សុខហេង បុគ្គលិក

គ - នាយកដ្ឋានទ្រព្យរដ្ឋ :

១-លោក ហែម ស៊ីថន បុគ្គលិក

២-លោក ទ្រី សេង បុគ្គលិក

៣-លោក ម៉ែន មុំលី បុគ្គលិក

៤-លោក អ៊ុច សាខន បុគ្គលិក

៥-លោក ស ស៊ុយអ៊ុង បុគ្គលិក

ឃ - នាយកដ្ឋានថវិការដ្ឋ :

១-លោក ម៉ែន ធុត្ថា បុគ្គលិក

២-លោក ខិន រិទ្ធី បុគ្គលិក

៣-លោក ម៉ៀង ទិសុទ្ធ បុគ្គលិក

៤-លោក អ៊ុក សុផា បុគ្គលិក

៥-លោកស្រីឡាយ សុផា បុគ្គលិក

ង - នាយកដ្ឋានហិរញ្ញកិច្ច :

១-លោក ឈី ហេង អនុប្រធានការិយាល័យ

២-លោក និន សុវណ្ណា បុគ្គលិក

៣-លោក ហ៊ីង ចន្ទ័ទូច បុគ្គលិក

៤-លោក សាន សឿន បុគ្គលិក

៥-លោក ឃុំ គឹក បុគ្គលិក

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចក្នុងប្រការ ១ និង ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

២ - ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ ២៧៦ ប្រក.សហវ.ពដ

ស្តីពី

ការកំណត់ពន្ធចំពោះអាជីវកម្មនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើអោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

- បានឃើញក្រឹត្យច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម លេខ ១១ នស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញប្រកាសលេខ ០២៦ ប្រក.សហវ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់បញ្ជាក់សកម្មភាពដែលជាប់ពន្ធតាមរបបពន្ធលើប្រាក់ចំណេញ និង អាករលើផលរបរ ,
- យោងតាមស្ថានភាពអាជីកម្មនេសាទ នាពេលបច្ចុប្បន្ននេះ ។

សំរេច

ប្រការ ១ : មុននឹងចូលរួមក្នុងការដេញថ្លៃជួលឡូត៍នេសាទធ្វើអាជីវកម្ម គ្រប់អាជីវករត្រូវបង្ហាញប័ណ្ណប៉ាតង់ ព្រមទាំងមានការបញ្ជាក់ពីអង្គភាពពន្ធដារថា បានបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ ។

ប្រការ ២ : អ្នកដេញថ្លៃបានមានកាតព្វកិច្ចត្រូវបង់ :

- អាករលើផលរបរ និង ពន្ធលើប្រាក់ចំណេញរួមគ្នា ដោយកំណត់ម៉ៅការយក ៥ % ពីលើថ្លៃឈ្នួលឡូត៍នេសាទដែលដេញបាន និង ត្រូវប្រកាសបង់ជូនអង្គភាពពន្ធដារនៅមូលដ្ឋានដែល ឡូត៍នេសាទតាំងនៅតាមកាលបរិច្ឆេទព្រម ៗ គ្នាជាមួយនឹងកាលបរិច្ឆេទនៃការបង់ប្រាក់ថ្លៃឈ្នួលឡូត៍នេសាទ ដែលបានកំណត់ក្នុងសៀវភៅបន្ទុក ។

ប្រការ ៣ : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ ៨ ឆ្នាំ ១៩៩៤

ប្រកាស លេខ ២៧៩ ប្រក.សហវ.ឋ

ស្តីអំពីការបង់ទេយ្យផលមាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រ កាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអាយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខណ្ឌ ជូនបណ្តាក្រសួងតាមឥណទាន ចែងក្នុងច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងសុខាភិបាល លេខ ១១៤៥ សកគន ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៥ និង លេខ ១៣២៤ សកគន ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង់ថវិកា របស់ក្រសួងសុខាភិបាល សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទាន ដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន កើន	ការកែប្រែឥណទាន ថយ	ស្ថានភាពឥណទានថ្មី
				ការបង្វែរពីជំពូក ១១			50.000	
11	01	14	01	ឱសថសំរាប់មន្ទីរពេទ្យ	7.361.000	-	50.000	7.311.000
				ផលប្រយោជន៍ជំពូក ១១		50.000	-	
11	01	14	05	ឧស្ម័នអុកស៊ីហ្សែន	25.000	50.000	-	75.000
				ការបង្វែរពីជំពូក ៣១			80.000	
31	01	02	01	អាហារូបករណ៍ស្រាវជ្រាវ	130.000	-	80.000	50.000
				ផលប្រយោជន៍ជំពូក ៣១		80.000		
31	01	02	02	អាហារូបករណ៍មហាវិទ្យាល័យ	-	46.000	-	46.000
31	01	02	03	អាហារូបករណ៍ពិធីសិក្សាធានា	-	34.000	-	34.000

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាអ្នកទទួលបន្ទុកក្នុងការអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាយ ថន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៨២ ប្រក.សហវ.ថ

ស្តីអំពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ .
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ជូនបណ្តាក្រសួងតាមឥណទាន ចែងក្នុងច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ .
- បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥ .

– តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ៨៨០ សហវ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកា របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១			5,000	
11	01	01	02	ការរៀបចំ និង ថែទាំ	350,000	-	5,000	345,000
				ផលប្រយោជន៍ជំពូក ១១		5,000		
11	02	02	04	សោហ៊ុយចំណាយផ្សេងៗ	-	5,000	-	5,000

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកទទួលបន្ទុកក្នុងការអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គាយ ឋន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ ១៩៩៥

ប្រកាស លេខ ២៨៥ ប្រក.សហវ.ថ

ស្តីអំពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល .
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ .
- បានឃើញព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ជូនបណ្តាក្រសួងតាមឥណទាន ចែងក្នុងច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ព្រះបរមរាជវាំង លេខ ២៥៥ រវ.លស ចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង្ងថវិកា របស់ព្រះបរមរាជវាំង សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវ ការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខណ្ឌ	វាក្យខណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១			102.000	
11	01	04		ក្រដាសបោះពុម្ពនិងសម្ភារៈការិយាល័យ	480.000	-	80.000	400.000
11	02	02	02	សោហ៊ុយបេសកកម្ម « ក្រៅប្រទេស »	55.000	-	22.000	33.000
				ផលប្រយោជន៍ជំពូក ១១		102.000	-	
11	01	03		សោហ៊ុយគមនាគមន៍ ទូរស័ព្ទតេឡិចទូរសារ ប្រៃសណីយ៍	117.500	80.000	-	197.500
11	02	02	04	សោហ៊ុយផ្សេងៗ ក្រៅប្រទេស	35.000	22.000	-	57.000

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រី ព្រះបរមរាជវាំង ជាអ្នកទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គាយ ច័ន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២៨៦ ប្រក.សហវ.ថ

ស្តីអំពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែល ប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែល ប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញ អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងព័ត៌មាន លេខ ៧៤៦/៩៥ ពម. ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងព័ត៌មាន សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន កើន	ការកែប្រែឥណទាន ថយ	ស្ថានភាពឥណទានថ្មី
				ការបង្វែរពីជំពូក ១១			15.000	
11	01	13		ការឃោសនា និងផ្សព្វផ្សាយ	508.500	-	15.000	493.500
				កសិកម្មសាធារណៈ				
				ផ្ទេរមកបង្គ្រប់ជំពូក ១១		15.000		
11	02	02	01	សោហ៊ុយដឹកជញ្ជូន	20.000	15.000	-	35.000

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

តាយ ឥន

* * *

២ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែនិង ថាមពល

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៥៤ ឧស.ប្រក

***

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុន ធនធានរ៉ែនៅតំបន់ **មេមង់ ខេត្តមណ្ឌលគិរី** ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៣
- បានឃើញពាក្យស្នើសុំលិខិតអនុញ្ញាតស្វែងរុករកធនធានរ៉ែ បន្តជាលើកទី ២ របស់ក្រុម ហ៊ុន **សាន់ត្រេឌីង** (SUNTRADING Co.,Ltd) លេខ ៣៦ សក្រន ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : អនុញ្ញាតិអោយក្រុមហ៊ុន SUNTRADING Co.,Ltd មានអាស័យដ្ឋានផ្ទះ លេខ ១០ ផ្លូវលេខ ៣៩២ សង្កាត់បឹងកេងកងទី ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើប្រតិបត្តិការស្វែងរុករកធនធានរ៉ែនៅតំបន់**មេមង់ ខេត្តមណ្ឌលគិរី** លើ ផ្ទៃដី ៩៤ គីឡូម៉ែត្រ ក្រឡា មានកូអរដូណេតទៅ ÷

ចំណុច	ខ្សែរយៈទទឹង	ខ្សែរយៈបណ្តោយ
A	12°37'30" N	106°50'00" E
B	12°37'30" N	106°55'00" E
C	12°32'00" N	106°55'00" E
D	12°32'00" N	106°50'00" E

ប្រការ ២ : ក្រុមហ៊ុន SUNTRADING Co.,Ltd ត្រូវដំណើរការការងារស្វែងរុករកធនធានរ៉ែ ជាលើកទី ២ លើផ្ទៃដីដែលបានកំណត់នេះ ដោយធានានូវលក្ខការណ៍បច្ចេកទេស ភូគព្ភសាស្ត្រ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃដល់ថ្ងៃទី ១១ មករា ១៩៩៧ ។ ផុតកំណត់ពេលនេះ ក្រុមហ៊ុន ត្រូវដាក់ពាក្យសុំការអនុញ្ញាតធ្វើការប្រតិបត្តិការស្វែងរុករកធនធានរ៉ែបន្ត ។ ក្នុងករណី ប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានល័ក្ខខ័ណ្ឌ ។

ប្រការ ៤ : ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ-រ៉ែ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច

ប្រធាន មន្ទីរនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តមណ្ឌលគីរី និង ប្រធានក្រុមហ៊ុន SUNTRADING Co.,Ltd ត្រូវ ទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរៈ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៩៨ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយរោងផលិតផល គ្រឿង ដែលមានលោក **ហុង សុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៦៧០៨ ក.ធ ចុះថ្ងៃទី ២៩ – ០១–៨៦ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិទី ៦ សង្កាត់លេខ ១ ទីរួម ខេត្តកំពង់ឆ្នាំង ខេត្ត កំពង់ឆ្នាំង បើកដំណើរការផលិតកម្មនៅក្នុងទីតាំងភូមិ ទី ៧ សង្កាត់លេខ ៤ ទីរួម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៦០០ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **តាំង គុយលីម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៩៩៨២ ក.ព ចុះថ្ងៃទី ១១–១២–៨៤ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១២១អឺ០ ផ្លូវលេខ ១៣៨ ក្រុមទី ៩ សង្កាត់ទឹកល្អក់ទី ១

ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មផលិតគ្រឿងក្រអូប សញ្ញា «សូរិយា» នៅ ក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **តាំង គួយលីម** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ដូចតទៅ : ទឹកអប់ SORIYA « BONJOUR D'ANGKOR », ទឹកអប់ «DALIA», ទឹកអប់«APSARA» និង សាប៊ូកក់សក់ «SORIYA» ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណី ប្រព្រឹត្តល្មើស ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះ នឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៦០៦ ឧក.ប្រក

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ ទ័រ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១២៦៤១១ ភ.ព ចុះថ្ងៃទី ៣១-៥-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩អា ផ្លូវលេខ ៤៣២ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើក ដំណើរការ សិប្បកម្មកែច្នៃស្រាស្ទូនីវិស្គី «SONY WHISKY» នៅក្នុងទីតាំង ផ្ទះ លេខ ៥ ផ្លូវលេខ ៤៣២ ក្រុមទី ១៤ សង្កាត់ បឹងត្របែង ខ័ណ្ឌចំការមន រាជធានី ភ្នំពេញ ។

ប្រការ ២ : លោក **សុខ ទ័រ** ត្រូវផលិតផលស្រាកែច្នៃចំនួនបីមុខ គឺស្រា «ស្ទូនីវិស្គី», ស្រា «ខ្លាខិន» និងស្រា «វិស្គីរប៉ាមសារី» ស្របតាមគំរូផ្លាកសញ្ញាដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋាន ត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណី

ប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាព ...
ឬ បង្កអោយមាន ការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ
ដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរៈ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៦០៧ មឈ.ប្រក

ស្តីពីការបង្កើតគណៈកម្មការរៀបចំគំរោងការតាំងពិពណ៌ WORLDTECH' 95 នៅប្រទេសថៃឡង់ដ៍

***

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតលេខ ១០៧១ សជណ.ផក ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពី ការចូលរួមតាំងពិពណ៌ WROLDTECH' 95 នៅប្រទេសថៃឡង់ដ៍
- បានឃើញការចាំបាច់របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយដើម្បីរៀបចំគំរោងការតាំងពិពណ៌ WROLDTECH' 95 នៅប្រទេសថៃឡង់ដ៍ ដែលមានសមាសភាពដូចខាងក្រោម ៈ

១–ឯកឧត្តម	**ហ៊ិល លីម**	អនុរដ្ឋលេខាធិការ	ប្រធាន
២–លោក	**ខ្ងន នៅ**	ប្រធាននាយកដ្ឋានផែនការ	អនុប្រធាន
៣–លោក	**ហ្វ ម៉ិច្ឆៃ**	ប្រធាននាយកដ្ឋានបច្ចេកទេស	អនុប្រធាន
៤–លោក	**ម៉ែន ឈានុះ**	ប្រធានការិយាល័យឧស្សាហកម្ម សិប្បកម្ម	សមាជិកអចិន្ត្រៃយ៍
៥–លោក	**ស្វែ ទីធកុណា**	ប្រធាននាយកដ្ឋាន រ៉ែ និង ភូគព្ភសាស្ត្រ	សមាជិក
៦–លោក	**ញ៉ឹក ឆ្នុំខ**	ប្រធាននាយកដ្ឋាន ថាមពល	សមាជិក
៧–លោក	**ប៊ុន លាន**	ប្រធាននាយកដ្ឋាន គណនេយ្យ ហិរញ្ញវត្ថុ	សមាជិក
៨–លោក	**ម៉ាក់ ម៉ាន់ឌី**	ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្ដាល	សមាជិក
៩–លោក	**ស្វន សេខម្ភត**	អនុប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ	សមាជិក
១០–លោក	**ស្វ សៃលាន**	មន្ត្រី នាយកដ្ឋានបច្ចេកទេស	សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចរៀបចំគំរោង សំរបសំរួល និង ដោះស្រាយរាល់ការងារ ដែលទាក់ទងនឹងការតាំងពិពណ៌ WROLDTECH' 95 នៅប្រទេសថៃឡង់ដ៍ ដើម្បី ដាក់ជូនទៅគណៈកម្មការអន្តរក្រសួងពិនិត្យ និង សំរេច ។

ប្រការ ៣ : ប្រធានមន្ទីរនៃទីស្ដីការ ព្រមទាំងសាមីជនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តក្នុងក្រមខ័ណ្ឌភារកិច្ចរៀងៗ ខ្លួន តាមប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

រាជធានីភ្នំពេញ ; ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩[illegible]

ប្រកាសលេខ ៦០៨ ឧក.ប្រក

១ : អនុញ្ញាតអោយអ្នកស្រី **ខ្ចូត សំផល** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧៤៤៩៣ បប ចុះថ្ងៃទី ០៧-១០-៨៧ អាស័យដ្ឋានបច្ចុប្បន្នភូមិ២០ ឧសភា សង្កាត់ឯកភាព ទីរួមខេត្តបាត់ដំបង ខេត្តបាត់ដំបង បើកដំណើរការ ឡផលិតអិដ្ឋ ក្បឿង នៅក្នុងទីតាំង ភូមិគោកពន្លៃ សង្កាត់អូរម៉ាល់ ទីរួមខេត្ត បាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរៈ

* * *

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៦៦/៩៥ ពម.ប្រក

ស្តីពីការផ្ទេរការងាររបស់មន្ត្រីរាជការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- ពិនិត្យលើសំណូមពរការងារចាំបាច់

ប្រការ ១ : ផ្ទេរមន្ត្រីរាជការចំនួន ០១ រូប គឺលោក សាន ហួត ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អោយទៅបំរើការងារនៅអគ្គនាយកដ្ឋានកាសែតកម្ពុជា ។

ប្រការ ២ : បាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួនត្រូវបានទទួលនៅ អគ្គនាយកដ្ឋានកាសែតកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : អគ្គនាយកដ្ឋានកាសែតកម្ពុជា ត្រូវរៀបចំសម្រួលបែងចែកភារកិច្ចជូន សាមីខ្លួនខាងលើអោយបានសមស្រប ។

ប្រការ ៤ : អគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានកាសែតកម្ពុជា នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល និងសាមីខ្លួនត្រូវអនុវត្តតាមប្រការនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខៈ ១៦៧/៩៥ ពម.ប្រក

ស្តីពីការផ្ទេរការងាររបស់មន្ត្រីរាជការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- ពិនិត្យលើសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១ : ផ្ទេរមន្ត្រីរាជការចំនួន ០១ រូប គឺលោក វ៉ាំង-សុង មន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អោយទៅបំរើការងារនៅអគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួនត្រូវបានទទួលនៅ អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា ត្រូវរៀបចំសំរួលបែងចែកភារកិច្ចជូនសាមី ខ្លួនខាងលើអោយបានសមស្រប ។

ប្រការ ៤ : អគ្គនាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា នាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៧០/៩៥ ពម.ប្រក

ស្តីពីការទទួលស្គាល់មន្ត្រី រាជការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីប្រកាសលេខ ២៣៦ សកប ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីការផ្លាស់ប្តូរមន្ត្រីរាជការ ពីក្រសួងសុខាភិបាល មកក្រសួងពត៌មាន
- យោងតាមភារកិច្ចចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : យល់ព្រមនិងទទួលស្គាល់ លោក អៀង-ជេដ្ឋ ជាមន្ត្រីរាជការក្រសួងសុខាភិបាល អោយមកបំពេញការងារនៅមន្ទីរពត៌មានខេត្ត ព្រៃវែង ជាអនុប្រធានមន្ទីរ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ សាមីជនត្រូវទទួលនៅមន្ទីរពតិមានខេត្ត ព្រៃវែង នៅពេលដែលក្រសួងសុខាភិបាលផ្ទេរវិញ្ញាបនប័ត្រផ្តាច់និងផ្ទេរមកអង្គភាព ថ្មី ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មន្ទីរពតិមានខេត្តព្រៃវែង និង លោក អៀង-ជេដ្ឋ មានភារៈអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៧៦/៩៥ ពម.ប្រក

ស្តីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ របស់ក្រសួង

- បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ ស្តីពីការកែលំអបៀវត្ស កម្មាភិបាល-បុគ្គលិក-កម្មកររដ្ឋ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩២
- យោងតាមសំណើរបស់ អគ្គនាយកដ្ឋានកាសែតកម្ពុជា លេខ ៧៨ កសក.បល ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៩៥
- តាមការពិនិត្យលើលក្ខណៈសម្បត្តិរបស់សាមីខ្លួន

សម្រេច

ប្រការ ១ : ទទួលស្គាល់ លោក សាត-សុផល អ្នកកាសែតថ្នាក់ឧត្តម ជាតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ របស់ អគ្គនាយកដ្ឋានកាសែតកម្ពុជា នៃ ក្រសួងពតិមាន ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវបានទទួលមួយរយភាគរយតាមការកំណត់របស់រដ្ឋ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ នេះតទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋានកាសែតកម្ពុជា នាយកដ្ឋានរដ្ឋបាលបុគ្គលិក នាយកដ្ឋានគណនេយ្យ ផែនការ ហិរញ្ញកិច្ច និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៧៧/៩៥ ពម.ប្រក

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជាជំពូកអវសានប្បញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មាន ដែលរដ្ឋសភា នៃរដ្ឋកម្ពុជា អនុមត័នាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតអនុញ្ញាត ជាគោលការណ៍លេខ ៩៩២-៩៤ ពម ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់ក្រសួងពត៌មាន ចំពោះលោក ព្រហ្ម ខេមរៈ
- បានឃើញ លិខិត ចុះថ្ងៃទី ២២-៦-១៩៩៤ របស់លោក **ព្រហ្ម ខេមរៈ** ស្នើសុំផ្ទេរ សិទ្ធិចាងហ្វាងការផ្សាយកាសែត «សម្រែករាជសីហ៍» ជូនមកលោក **ម៉ាន់ ឧល្លុន** វិញ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ព្រាប ខេមរៈ** ផ្ទេរសិទ្ធិចាងហ្វាងការផ្សាយសារពត៌មាន «សម្រែករាជ សីហ៍» អោយទៅឈ្មោះ **ឆាន់ ឥល្លូន** ដែលជាអតីតៈចាងហ្វាង នយោបាយសារពត៌មាន ខាងលើនេះវិញ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ ប្រពៃណី ល្អ និង ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា

ប្រការ ៣ : គោរពតាមគោលការណ៍ ក្រមសីលធម៌ អ្នកកាសែត និងឈរលើស្មារតីទទួល ខុសត្រូវ ខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និង ប្រគល់កាសែតចំនួន ១៥ ច្បាប់រៀង រាល់លេខចេញ ផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **ឆាន់ ឥល្លូន** ចាងហ្វាងការផ្សាយសារពត៌មាន «សម្រែករាជសីហ៍» និង នាយក ដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៧៨/៩៥ ពម.ប្រក

ស្តីពី ការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង

– បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

– បានឃើញ អនុក្រឹត្យ ស្តីពីការកែលំអរបៀវត្ស កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩២

- យោងតាមសំណើសុំលុបឈ្មោះរបស់អគ្គនាយកដ្ឋានវិទ្យុជាតិ លេខ ៨៥ បល ចុះថ្ងៃទី ២៩ ខែ ០៦ ឆ្នាំ ១៩៩៥
- ពិនិត្យលើសំណូមពររបស់សាមីខ្លួន

សំរេច

ប្រការ ១ : លុបឈ្មោះ លោកស្រី **សុខ រស្មី** ជាបុគ្គលិក បានចូលបំរើការងារពីថ្ងៃទី ១០ ខែ ១១ ឆ្នាំ ១៩៨១ ចេញពីក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋានវិទ្យុជាតិនៃក្រសួងពត៌មានចាប់ពីថ្ងៃទី ០១–៩–១៩៩៥ តទៅ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ សាមីខ្លួន ត្រូវបានទទួលម្តងគត់ គឺស្មើនិង ប្រាក់បៀវត្សសរុបក្នុង ១ខែ គុណនឹងចំនួនឆ្នាំបំរើការងារដែលមាន ដូចខាងក្រោម នេះ ÷

- លោកស្រី **សុខ រស្មី** : ៣០.៨១០៛ គុណ ៩ = ២៧៧.២៩០៛០០

ប្រការ ៣ : អគ្គនាយកដ្ឋាន វិទ្យុជាតិ នាយកដ្ឋានរដ្ឋបាលបុគ្គលិក នាយកដ្ឋានគណនេយ្យ ផែនការ ហិរញ្ញកិច្ច និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះ ហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៧៩ ពម.ប្រក

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានប្បញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម **សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញច្បាប់សារពត៌មាន ត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជា អនុម័តនាសម័យប្រជុំ វិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតរបស់លោក សៅ ចណ្ណារិន ស្នើសុំអនុញ្ញាតបោះពុម្ពផ្សាយទស្សនាវដ្ដីប្រចាំឆ្នាំ THE BUSINESS NEWS GUIDE ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយដំណើរការបោះពុម្ពចែកផ្សាយទស្សនាវដ្ដីប្រចាំឆ្នាំឈ្មោះ «THE BUSINESS NEWS GUIDE » ជាភាសាអង់គ្លេស និងខ្មែរ ដោយមានលោក **សៅ ចណ្ណារិន** ជា ចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់ លើវិជ្ជាជីវៈរបស់ខ្លួន រួចស្នើប្រគល់ទស្សនាវដ្ដី នេះចំនួន ១៥ ច្បាប់ រៀងរាល់លេខ មក តំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោកចាងហ្វាងការផ្សាយទស្សនាវដ្ដី « THE BUSINESS NEWS GUIDE » និង នាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៨០/៩៥ ពម.ប្រក

ស្ដីពីការទទួលស្គាល់មន្ត្រីរាជការ

- បានឃើញ ព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម **សីហនុវរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងប្រកាសលេខ ៤២៩ ប្រ.ក.វ.វ.ស.៩ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ
- ពិនិត្យលើការយល់ព្រមទទួលរបស់ អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា
- ពិនិត្យលើសំណើរបស់សាមីខ្លួន

សំរេច

ប្រការ ១ : យល់ព្រម និង ទទួលស្គាល់អ្នកស្រី **មាស មូលី** អនុប្រធានមន្ទីរ ផ្ទេរមក ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ អោយទៅបំរើការងារនៅ អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិ កម្ពុជា នៃក្រសួងពត៌មាន ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន អគ្គនាយកដ្ឋាន ទូរទស្សន៍ ត្រូវរៀបចំសំរួលបញ្ចូលបៀវត្ស គិតចាប់ពីថ្ងៃដែលក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ផ្ទេរមក ក្រសួងពត៌មាន ។

ប្រការ ៣ : អគ្គនាយកដ្ឋាន ទូរទស្សន៍ ត្រូវសំរួលបែងចែកភារកិច្ចជូនអ្នកស្រី មាស-មូលី អោយ សមស្របតាមសមត្ថភាព ។

ប្រការ ៤ : អគ្គនាយកដ្ឋានទូរទស្សន៍ នាយកដ្ឋានបុគ្គលិក-រដ្ឋបាល នាយកដ្ឋានផែនការ គណនេយ្យ- ហិរញ្ញវត្ថុ និង សាមីខ្លួន មានភារៈអនុវត្តតាមប្រកាសនេះ ចាប់ពី ថ្ងៃចុះ ហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

៤ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សារាចរ

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៥

សារាចរ លេខ ០៣ សរច

ស្តីពីការបើកមហោស្រពតែងនិពន្ធអក្សរសិល្ប៍

«ព្រះរាជសម្ភារ»

អនុវត្តតាមស្មារតីអង្គសិក្ខាសាលាទិវាវប្បធម៌ លើកទី២ និង ផ្អែកលើផែនការការងាររបស់ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ សំរាប់ឆ្នាំ ១៩៩៥ -១៩៩៦ ក្រសួងមាន ភារកិច្ចបំផុសចលនាប្រឡងប្រណាំងអក្សរសាស្ត្រ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីអបអរ សាទរ ចំពោះជោគជ័យ និង ជំហានអភិវឌ្ឍន៍ថ្មីរបស់ព្រះរាជាណាចក្រកម្ពុជា និង អបអរ សាទរ ចំពោះទិវាវប្បធម៌ លើកទី ៣ របស់ក្រសួង ។

១–គោលបំណង :

– បំផុសប្រជារាស្ត្រ មហាជន មន្ត្រីរាជការ និយោជិត កម្មករ សិល្បៈករ និង កងកំលាំងប្រដាប់អាវុធទាំងអស់ អោយឃើញពីជ័យជំនះដ៏ធំធេងរបស់ព្រះរាជាណាចក្រ កម្ពុជា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកន្លងមក ដើម្បីផ្តើមចេញពីនោះ ពលរដ្ឋម្នាក់ៗ មើលឃើញ និងកំណត់ច្បាប់នូវទីតាំង តួនាទី និង កាតព្វកិច្ចរបស់ខ្លួនចំពោះមាតុភូមិ ខិតខំ កសាងស្នាដៃបំរើសង្គម និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជារាស្ត្រ ។

– រិះគន់ និង កែលំអ នូវទស្សនៈអសកម្មមួយចំនួន ដែលនាំអោយយឺតយ៉ាវដល់ ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ជាតិ ផ្តើមចេញពីនោះ ស្តារនិងកសាងឡើងវិញ នូវចរិតដ៏ល្អប្រពៃ នូវទម្រង់ និង ...តប្រពៃណីវប្បធម៌ជាតិអោយបានគង់វង់ ចិតថេរ និង រុងរឿងជាដរាប ។

២-អំពីរូបភាពតែងនិពន្ធ :

១- រឿងប្រលោមលោក

២- រឿងល្ខោន

៣- កំណាព្យ

៣-អំពីខ្លឹមសារ :

- ស្នាដៃតែងនិពន្ធ ដែលចូលរួមប្រឡងក្នុងមហោស្រពអក្សរសិល្ប៍ «ព្រះរាជ សម្ភារ» នេះត្រូវឆ្លុះបញ្ចាំងតាមខ្លឹមសារដូចខាងក្រោមនេះ ÷

ក- បំផុសស្មារតី អោយមានជំនឿជាក់ លើការដឹកនាំរបស់រាជរដ្ឋាភិបាល ។

ខ- បំផុសស្មារតី ចូលរួមសកម្មក្នុងការបំរើប្រទេសជាតិ និងមានជំហរទទួល ខុសត្រូវចំពោះជាតិមាតុភូមិ ។

គ- បណ្តុះសីលធម៌ជាតិ គតិបណ្ឌិតជាតិ រិះគន់ភាពអសីលធម៌ អគតិបណ្ឌិត និង អមនុស្សធម៌ទាំងឡាយ ។

ឃ- បំផុសស្មារតី ស្នេហាវប្បធម៌ជាតិ និងចូលរួមថែរក្សាលើក ដំកើងខឿន វប្បធម៌ជាតិ ។

៤-គោលការណ៍កំណត់ :

១-អំពីកាលបរិច្ឆេទ :

- វគ្គប្រឡងប្រជែងមហោស្រពអក្សរសិល្ប៍ «ព្រះរាជសម្ភារ» នេះ ចាប់ផ្តើម ទទួលស្នាដៃ ចាប់ពីពេលចេញសេចក្តីប្រកាសនេះទៅ រហូតដល់ទី ៣០ ធ្នូ ១៩៩៥ ទើបឈប់ ទទួលស្នាដៃចូលប្រឡង ។

២-លក្ខណ៍និពន្ធ :

ខ្លឹមសារណែនាំខាងលើ គ្រាន់ជាបន្ទាត់ត្រួសត្រាយសំរាប់ការនិពន្ធប៉ុណ្ណោះ ប៉ុន្តែប្រធានបទទាំងឡាយសំរាប់ប្រលោមលោក រឿងល្ខោន និង កំណាព្យ អ្នកនិពន្ធទាំងអស់ អាចមានសិទ្ធិជ្រើសរើសមកសរសេរបានដោយសេរី ហើយមិនកំណត់កំរិតទំព័រទៀតផង ពោលគឺ សរសេរប្រវែងប៉ុណ្ណាក៏បាន តែត្រូវសរសេរនៅក្នុងសៀវភៅ ដើម្បីងាយស្រួលក្នុង ការផ្ញើចុះឡើង ។

៣–អំពីការសរសើរជូនរង្វាន់ :

ស្នាដៃនិពន្ធដែលបានចូលរួមក្នុងមហោព្រអក្សរសិល្ប៍ «ព្រះរាជសម្ភារ» នេះត្រូវបានគណៈកម្មការពិនិត្យមួយ : ដែលចាត់តាំងឡើងដោយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សហការជាមួយសមាគមអ្នកនិពន្ធកម្ពុជាពិនិត្យ និង ចំរាញ់ចំណាត់ថ្នាក់ជា ៣ ប្រភេទ គឺ ÷

- លេខ ១ – លេខ ២ – លេខ ៣ ខាងប្រលោមលោក
- លេខ ១ – លេខ ២ – លេខ ៣ ខាងរឿងល្ខោន
- លេខ ១ – លេខ ២ – លេខ ៣ ខាងកំណាព្យ
- រង្វាន់លេខ ១ ត្រូវបានទទួល មេដាយមាសមួយ និង រង្វាន់អម
- រង្វាន់លេខ ២ ត្រូវបានទទួល មេដាយប្រាក់មួយ និង រង្វាន់អម
- រង្វាន់លេខ ៣ ត្រូវបានទទួល មេដាយសំរិទ្ធមួយ និង រង្វាន់អម
- ចំពោះស្នាដៃដែលបានទទួលចំណាត់ថ្នាក់ជាបន្តបន្ទាប់ និង មានរង្វាន់លើក ទឹកចិត្ត ។

ទទួលបានសារាចរនេះ សូមលោកប្រធានគ្រប់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត–ក្រុង ធ្វើការផ្សព្វផ្សាយអោយបានជ្រួតជ្រាបដល់មហាជនប្រជារាស្ត្រ មន្ត្រីរាជការ កម្មករ សិល្បករ កងទ័ព ដើម្បីបង្កើតស្នាដៃចូលរួមក្នុងមហោស្រពនេះ ។

មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត – ក្រុង ត្រូវមានភារកិច្ចជួយបង្កលក្ខណៈ ងាយស្រួល និង ប្រមូលស្នាដៃនិពន្ធទាំងអស់ផ្ញើមក ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ «នាយកដ្ឋានបោះពុម្ពផ្សាយវប្បធម៌ ការអាន និង ដឹកលំឯកសារ» អោយបានទាន់មុនថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៥ ដើម្បីក្រសួងចាត់តាំងគណៈកម្មការត្រួតពិនិត្យវាយតំលៃ និង ជូន រង្វាន់តាមកំរិតស្នាដៃ ។

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
ហត្ថលេខា និង ត្រា
នុត ណារាង

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៥

សារាចរណែនាំ លេខ: ០៤ សរណន

ស្តីអំពីការការពារបេតិកភណ្ឌជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា

ប៉ុន្មានឆ្នាំកន្លងមកនេះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានយកអស់ស្មារតីក្នុងកិច្ចការពារនិងថែរក្សាបេតិកភណ្ឌជាតិ ទៅតាមទិសដៅ របស់រាជរដ្ឋាភិបាល ។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបាន រិះរកគ្រប់មធ្យោបាយ ដោយសហការយ៉ាងជិតស្និទ្ធជាមួយកងប្រដាប់អាវុធ មាននគរបាល កងទ័ព រដ្ឋ អំណាច និងប្រជាពលរដ្ឋ ដើម្បីទប់ស្កាត់ការលួចប្លន់ជីកកកាយ និង ដាប់ឬវាយយកវត្ថុបូរាណទៅលក់អោយឈ្មួញទុច្ចរិត ។

ប៉ុន្តែមួយរយៈនេះក្រសួងវប្បធម៌ និង វិចិត្រសិល្បៈមានការសោកស្តាយយ៉ាងខ្លាំងចំពោះសកម្មភាព លួចប្លន់ជីកកកាយ និងដាប់ឬវាយយកវត្ថុបូរាណរឹតតែខ្លាំងក្លាថែមទៀត ។

ដូច្នេះក្រសួងវប្បធម៌និងវិចិត្រសិល្បៈសូមអំពាវនាវដល់បងប្អូនរួមជាតិគ្រប់ជាន់ថ្នាក់ទូទាំងប្រទេសពួត ដៃគ្នា យ៉ាងពេញទំហឹងអស់ពីស្មារតីដើម្បីទប់ស្កាត់ និងជួយថែរក្សាការពារ សម្បត្តិវប្បធម៌ជាតិរបស់ ខ្លួនអោយបានគង់វង់ «បាត់បង់វប្បធម៌ គឺបាត់បង់ជាតិទាំងមូល» ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៦ មាត្រាទី ៦៩ ទី ៧០ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ដែលស្តីពីអំពី ការថែរក្សា និងការការពារសម្បត្តិវប្បធម៌ពិសេសប្រាសាទបូរាណវត្ថុសិល្បៈបូរាណ និងកែលំអរមណីយដ្ឋាន ប្រវត្តិសាស្ត្រឡើងវិញ ។

មាត្រាទី៧០ ជំពូកដដែល នៃរដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ថា «ជនល្មើសទាំងឡាយណាដែល ប៉ះពាល់ ឬទាក់ទងនឹងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌសិល្បៈត្រូវផ្តន្ទាទោសជាទម្ងន់ » ។

ដោយផ្អែកលើរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចបានពែងខាងលើ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈមានសំណូមពរដូចតទៅ :

១-គ្រប់ស្ថាប័ន-អង្គភាព ព្រះសង្ឃគ្រប់វត្ត រដ្ឋអំណាចក្រុង -ខេត្ត-ស្រុក ឃុំ-ភូមិ និងបណ្តាមន្ទីរ ទាំងអស់នៅក្នុងខេត្ត-ក្រុង សូមជួយសហការជាមួយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឬមន្ទីរវប្បធម៌ នៅតាមបណ្តាខេត្តនានា ចុះពន្យល់ ដល់ប្រជារាស្ត្រយើងនៅតាមតំបន់អោយស្គាល់ស្រឡាញ់ និងជួយថែ រក្សាការ ពារវប្បធម៌ជាតិអោយបានជាប្រចាំ ។

២-មន្ទីរវប្បធម៌ ខេត្ត-ក្រុង ត្រូវសហការជាមួយរដ្ឋអំណាច-នគរបាល កងខេមរភូមិន្ទដើម្បីទប់ស្កាត់ជាបន្ទាន់នូវការលួចប្លន់ គាស់កកាយ ជីក ដាប់ យកវត្ថុបូរាណនៅតាមប្រាសាទនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ហើយលើក វិធានការការពារនេះអោយបានពិស្តារ រួចផ្តល់មកក្រសួងជាបន្ទាន់ នូវប្រតិទិន អនុវត្តការងារនេះព្រមទាំងរបាយការណ៍ប្រញាប់ និង របាយការណ៍ប្រចាំខែទៅ តាមស្ថានភាព ។

៣-កងប្រដាប់អាវុធគ្រប់ប្រភេទ ដែលមានភារកិច្ចការពារតាមប្រាសាទ តាមតំបន់ ឬ តាមព្រំដែន មេត្តាមានវិធានការអោយបានតឹងរ៉ឹងបំផុតចំពោះជន ល្មើសដែលប្រព្រឹត្តផ្ទុយពីច្បាប់រដ្ឋ ដូចបានចែង ខាងលើ ។

៤-មិនត្រូវយកវត្ថុបូរាណមកដាក់តាមផ្ទះ វត្តអារាម ឬ តាមអង្គភាពណា មួយដែលគ្មានការអនុញ្ញាត ពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាដាច់ខាត ។

៥-ជនណាដែលបានប្រព្រឹត្តល្មើសពីច្បាប់រដ្ឋ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ ជាធរមាន ។

៦-ព្រះសង្ឃ អាចារ្យវត្ត និង ប្រជារាស្ត្រទាំងអស់ មានភារកិច្ចរាយការណ៍ ជាបន្ទាន់ដល់រដ្ឋអំណាច ចំពោះជនណាមួយ ឬ ក្រុមណាមួយដែលបានលួច ប្លន់ ជីក គាស់ កកាយ ដាប់ យកវត្ថុបូរាណ ឬ មានគំនិតបំផ្លិចបំផ្លាញសម្បត្តិ ទាំង អស់នោះ ។

៧-លើកទឹកចិត្តជូនរង្វាន់ចំពោះបុគ្គលណាដែលចាប់បានជនល្មើស ហើយយកវត្ថុបូរាណនោះមកជូន ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសង្ឃឹម និងជឿជាក់លើឯកឧត្តម អស់លោក ជាប្រធានបណ្តាគ្រប់ ស្ថាប័ន រដ្ឋអំណាចគ្រប់ជាន់ថ្នាក់ ប្រជារាស្ត្រ ព្រះសង្ឃ ពិតជាជួយសហការ ជាមួយក្រសួងយើងខ្ញុំ ។

សារាចរនេះ ត្រូវអនុវត្តអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

នុត ណារ៉ាង

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៤៤ ប្រក.វវស.ចុ

ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរវប្បធម៌

និងវិចិត្រសិល្បៈរាជធានីភ្នំពេញ

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល កម្ពុជា
- យោងតាមសំណើសុំលុបឈ្មោះលេខ ២៥៩ ឈ.ស ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់មន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ

សម្រេច

មាត្រា ១ : លោក **ម៉ុញ ល៉ឹម** ជាបុគ្គលិកការិយាល័យសិល្បៈផ្នែកល្ខោន នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ រាជធានីភ្នំពេញត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្របខ័ណ្ឌមន្ត្រីរាជការមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដោយមរណៈភាព ។

មាត្រា ២ : ខុទ្ទកាល័យអគ្គនាយកដ្ឋានរដ្ឋបាល និង មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីភ្នំពេញមាន ភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

នុត ណារ៉ាង

* * *

៥ - ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦១/៩៥ កធស-ប្រក

ស្តីពីការផ្ទេរមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌ

ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយ ប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និង សាសនា
- បានឃើញពាក្យស្នើសុំរបស់លោក **ម៉ិន មុខ** ចុះថ្ងៃទី ២៦ កក្កដា ១៩៩៥

សំរេច

ប្រការ ១ : លោក **ម៉ិន មុខ** បុគ្គលិកការិយាល័យគរុកោសល្យ អគ្គាធិការដ្ឋានពុទ្ធិកសិក្សា នៃក្រសួង ធម្មការ និងសាសនា ត្រូវផ្ទេរអោយទៅធ្វើការនៅមន្ទីរធម្មការ និង សាសនាខេត្តពោធិសាត់ ។

ប្រការ ២ : បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗរបស់លោក **ម៉ិន ហុង** ត្រូវផ្ទេរជូនមន្ទីរធម្មការ និងសាសនា ខេត្តពោធិសាត់ ។

ប្រការ ៣ : មន្ទីរធម្មការ និង សាសនាខេត្តពោធិសាត់ និង លោក **ម៉ិន ហុង** ត្រូវអនុវត្តតាមសេចក្ដី ប្រកាសនេះរៀងៗខ្លួន ។

ប្រការ ៤ : សេចក្ដីប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា

ហត្ថលេខានិងត្រា

ហៀន វណ្ណារិទ្ធ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្ដីសំរេចលេខ ១៦២/៩៥ កធស.នធ

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅនៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញពាក្យសុំបង្កើត «សមាគមដូនជី និងឧបាសិកាកម្ពុជរដ្ឋ » របស់ដូនជី **ទឹម ចន** គ្មាន ចុះថ្ងៃ ខែ ឆ្នាំ ។

សំរេច

ប្រការ ១ : ទទួលស្គាល់ «សមាគមដូនជី និងឧបាសិកាកម្ពុជរដ្ឋ » ដែលមានទីស្នាក់ការបណ្ដោះអាសន្ន នៅ....................... ។

ប្រការ ២ : សមាគមនេះ មានភារកិច្ចធ្វើការអប់រំផ្លូវចិត្ត ថែរក្សា និងផ្សព្វផ្សាយពុទ្ធសាសនាទៅតាមពុទ្ធ បញ្ញត្តិ និងពុទ្ធានុញ្ញាត ព្រមទាំងជួយបណ្ដុះបណ្ដាល និងឧបត្ថម្ភដល់ដូនជី ឧបាសិកាព្រមទាំងពុទ្ធ

សាសនិក អោយមានការអភិវឌ្ឍន៍ខាងចំណេះដឹងផ្លូវពុទ្ធចក្រ និងផ្លូវអាណាចក្រ ។

ប្រការ ៣ : សមាគមនេះ ត្រូវគោរពអោយបានត្រឹមត្រូវតាមមាតិកាព្រះពុទ្ធសាសនា និងច្បាប់របស់ព្រះ រាជាណាចក្រកម្ពុជា ព្រមទាំងរាល់បទបញ្ញត្តិទាំងឡាយរបស់ ក្រសួងធម្មការ និងសាសនា និងលក្ខន្តិកៈ សមាគម ។
ហាមដាច់ខាតមិនអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនាដទៃ និងសណ្តាប់ ធ្នាប់សង្គម ។

ប្រការ ៤ : សមាគមដូនជី និងឧបាសិកាកម្ពុជរដ្ឋ នាយកដ្ឋានធម្មការ និងមន្ទីរធម្មការ និងសាសនា គ្រប់ខេត្ត-ក្រុង និងស្ថាប័នរដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ត្រូវសហការអនុវត្តសេចក្តីសំរេច នេះ អោយបានល្អប្រសើរ ។

ប្រការ ៥ : សេចក្តីសំរេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

ហៀង ចន្ទរ័ត្ន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៤/៩៥ កធស.ប្រក
ស្តីពីការផ្ទេរមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនាដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និង សាសនា

- បានឃើញពាក្យសុំផ្ទេររបស់លោក **ឈឹម សុខ** ចុះថ្ងៃទី ២៩ កក្កដា ១៩៩៥

សម្រេច

ប្រការ ១ : លោក **ឈឹម សុខ** បុគ្គលិកនាយកដ្ឋានសាសនា នៃក្រសួងធម្មការ និងសាសនា ត្រូវផ្ទេរ អោយទៅធ្វើការនៅមន្ទីរធម្មការ និងសាសនា ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រវត្តិរូប និងឯកសារផ្សេងៗ របស់លោក **ឈឹម សុខ** ត្រូវផ្ទេរជូនមន្ទីរធម្មការ និង សាសនាខេត្តបាត់ដំបង ។

ប្រការ ៣ : មន្ទីរធម្មការ និងសាសនាខេត្តបាត់ដំបង និង លោក **ឈឹម សុខ** ត្រូវអនុវត្តតាមសេចក្តី ប្រកាសនេះរៀងៗខ្លួន ។

ប្រការ ៤ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

ហត្ថលេខា និងត្រា

ហៀង ធណ្ណារ័ត្ន

*

* *

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៧៥៦ រៀល